ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៣៧៦៣ មស. ស៩៧

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បេក្ខជនដែលបានបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំង៥ សម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម៖

**១-សម័យប្រឡង នៅថ្ងៃអាទិត្យ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦**
**មណ្ឌលប្រឡង៖ វិទ្យាល័យបាក់ទូក (រាជធានីភ្នំពេញ)**

→ **ម៉ោង ០៦:២០នាទី៖** បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង

→ **ម៉ោង ០៦:៤០នាទី ដល់ ម៉ោង ០៧:០០នាទី៖** អនុក្សរហៅឈ្មោះបេក្ខជនចូលបន្ទប់ ត្រួតពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន

→ **ម៉ោង ០៧:១៥នាទី ដល់ ម៉ោង ៩:១៥នាទី៖**
- វិញ្ញាសាចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ ទៅតាមប្រភេទក្របខណ្ឌ **ក ខ** និង**គ**
- វិញ្ញាសាចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ទៅតាមប្រភេទក្របខណ្ឌ **ក ខ** និង**គ**

→ **ម៉ោង ១០:០០នាទី ដល់ ម៉ោង ១១:៣០នាទី៖**
- វិញ្ញាសាភាសាអង់គ្លេសនិងកុំព្យូទ័រ ទៅតាមប្រភេទក្របខណ្ឌ **ក ខ** និង**គ** ទាំងប្រាំ ក្រសួង ស្ថាប័ន

២-បញ្ជីរាយនាមបេក្ខជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមប្រឡងមានបិទផ្សាយនៅក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ តទៅ។ បេក្ខជន បេក្ខនារី មានសិទ្ធិតវ៉ាមកអនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ នៅក្រសួងមុខងារសាធារណៈ ក្នុងករណីមិនមានឈ្មោះប្រឡង ឬបញ្ហាផ្សេងៗ ត្រឹមថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦។

៣-ចំពោះ**ប្លង់មណ្ឌលប្រឡង លេខបន្ទប់ និងលេខតុ** របស់បេក្ខជន បេក្ខនារីនឹងធ្វើការបិទផ្សាយនៅវិទ្យាល័យបាក់ទូក នាថ្ងៃសៅរ៍ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ០៩៖០០ នាទីព្រឹក។

អាស្រ័យហេតុនេះ សូមបេក្ខជន បេក្ខនារី ដែលមានឈ្មោះចូលរួមប្រឡង ត្រូវយកមកជាមួយនូវឯកសារដូចជា សលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសំគាល់ខ្លួនសិស្ស និស្សិត ជាដើម។

***បញ្ជាក់៖ គណៈកម្មការរៀបចំការប្រឡង រក្សាសិទ្ធិកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់។***

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

**រដ្ឋលេខាធិការនិងជា**
**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ម៉ាន់ ម៉ារ៉ា**

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៣២៤៥ មស.គ្រខ.

# សេចក្ដីសម្រេច
## ស្ដីពី
## ការអនុញ្ញាតឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ចូលរួមប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០១៦

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ៤៨៧ មស.គ្រខ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ៧១៣/១៦ ទរពអ.រប ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
- យោងលិខិតលេខ៥៨៣ លស.អរហ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ០៣៥៩ បទ.បប ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងលិខិតលេខ១៣៣៤ ធទឧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងលិខិតលេខ២១៤ គ.ជ.ទ.ម.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- យោងលិខិតលេខ១៥២/១៦ អទស ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់អាជ្ញាធរទន្លេសាប
- យោងលិខិតលេខ០២៩៨ រលអស ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

## សម្រេច

**ប្រការ ១៖** ត្រូវបានអនុញ្ញាតឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលចំនួន **២០៨៣នាក់** ចូលរួមប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖



ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh